**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅ**
**ចំប៉ា ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩**

# ខ្ញុំសុខចិត្តបម្រើអស់មួយជីវិត

| **អត្ថបទទី១៖ កិច្ចការ ៥,២៧-៣៣** |
| --- |
| លោកសិលា និងគ្រីស្តទូតឯទៀតៗឆ្លើយឡើងថា៖ «យើងខ្ញុំត្រូវស្តាប់បង្គាប់ព្រះជាម្ចាស់ជាជាងស្តាប់បង្គាប់មនុស្ស។ កក ៥,២៩ |
| **ដំណឹងល្អ៖ យ៉ូហាន ៣,៣១-៣៦** |
| អ្នកដែលទទួលសក្ខីភាពរបស់ព្រះអង្គបានបញ្ជាក់ថា ព្រះជាម្ចាស់បានសម្តែងសេចក្តីពិតមែន។ យហ ៣,៣៣ |

បងប្អូនជាទីស្រឡាញ់!

ព្រះសហគមន៍របស់យើង ត្រូវតែមានយុវជនយុវនារីគិតថា **តើអនាគតរបស់ខ្ញុំទៅជាអ្វី?** យើងអាចរិះគិតបានលុះត្រាតែនៅក្នុងគ្រួសារយើង មានឪពុកម្តាយ មានលោកតាលោកយាយ ដែលអធិដ្ឋាននិងណែនាំឲ្យកូនចូលវិហាររាល់អាទិត្យ ដែលបានបង្កើតបរិយាកាសនៅក្នុងក្រុមគ្រួសារដែលចេះស្រឡាញ់គ្នាទៅវិញទៅមក ជាពិសេសដែលចេះស្រឡាញ់ព្រះយេស៊ូ ដែលចេះស្រឡាញ់ព្រះនាងម៉ារី។ ប្រសិនបើ លោកតាលោកយាយ ឪពុកម្តាយ គ្រួសារ មិនជម្រុញមិនទៅមុខទេ ឪពុកម្តាយ លោកតាលោកយាយ សំខាន់ណាស់ព្រោះការគាំទ្រ ការលើកទឹកចិត្ត និងអធិដ្ឋានរបស់ពួកគាត់ដើម្បីឲ្យកូនចៅទៅមុខ នោះគេអាចទៅមុខបាន។

ការត្រាស់ហៅរបស់ខ្ញុំ គឺកើតមាននៅពេលខ្ញុំមានអាយុ៦ឬ៧ឆ្នាំ ដោយសារឪពុកម្តាយខ្ញុំរាល់ថ្ងៃអាទិត្យជូនខ្ញុំទៅចូលរួមអភិបូជា។ ខ្ញុំបានទទួលព្រះកាយព្រះគ្រីស្តលើកដំបូងពេលខ្ញុំមានអាយុ៧ឆ្នាំ ហើយនៅពេលខ្ញុំមានអាយុ៨ឆ្នាំម្តាយខ្ញុំបានឲ្យខ្ញុំចូលរួមពិធីតែងតាំងបូជាចារ្យចំនួន១០នាក់។ ទាំងអស់នេះណែនាំឲ្យចូលនៅក្នុងចិត្តខ្ញុំមែនទែន ណែនាំឲ្យខ្ញុំរិះគិតខ្ញុំចង់ធ្វើជាបូជាចារ្យដែរ ខ្ញុំចង់ធ្វើដូចលោកឪពុកម្នាក់ដែលនៅព្រះវិហារកំណើតរបស់ខ្ញុំមែនទែន។ ដូច្នេះ កូនៗនៅទីនេះកុំភ្លេចគិត យើងមានអាយុ៦ឆ្នាំ១០ឆ្នាំ ព្រះជាម្ចាស់កំពុងធ្វើការនៅក្នុងខ្លួនរបស់យើង។ យើងមានឪពុកម្តាយដែលណែនាំឲ្យយើងចូលព្រះវិហាររាល់អាទិត្យ ណែនាំឲ្យជីវិតរបស់យើងបន្តិចម្តងៗជាប់ជាមួយព្រះជាម្ចាស់។ អត្ថបទដំណឹងល្អថា "**អ្នកណាដែលជឿលើព្រះបុត្រា អ្នកនោះមានជីវិតអស់កល្បជានិច្ច**" **មូលហេតុអ្វីយើងចូលព្រះវិហាររាល់អាទិត្យ? មូលហេតុអ្វីយើងចូលអធិដ្ឋានរាល់ថ្ងៃ?** ដោយសារយើងជាសាវ័ករបស់ព្រះគ្រីស្ត យើងជាមិត្តសម្លាញ់របស់

ព្រះគ្រីស្ត យើងប្រកាសជំនឿរបស់យើងលើព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ នៅពេលនោះយើងនឹកឃើញព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញខ្ញុំជឿពិតមែន ណែនាំឲ្យខ្ញុំមានជីវិតអស់កល្បជានិច្ច។

យើងចូលអភិបូជា យើងមានទំនាក់ទំនងជាមួយព្រះយេស៊ូ យើងទទួលព្រះកាយនិងព្រះលោហិតព្រះគ្រីស្ត យើងស្តាប់អត្ថបទគម្ពីរដំណឹងល្អដែលជាព្រះបន្ទូលរបស់ព្រះអង្គ ដោយដឹងថាណែនាំឲ្យខ្ញុំភ្ជាប់ជាមួយព្រះយេស៊ូ។ ព្រះយេស៊ូណែនាំឲ្យយើងទទួលជីវិតលើផែនដីនេះមែន ប៉ុន្តែជាពិសេសព្រះអង្គបានណែនាំឲ្យខ្ញុំទទួលជីវិតអស់កល្បជានិច្ច។ សាសនានីមួយៗមានគំនិតផ្សេងៗពីគ្នាអំពីជីវិតអស់កល្បជានិច្ច សម្រាប់យើងដែលជាគ្រីស្តបរិស័ទកាតូលិក យើងជឿលើព្រះយេស៊ូដែលមានព្រះជន្មគង់នៅថ្ងៃនេះ ដោយសារព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ យើងដឹងថា ប្រសិនបើយើងផ្ញើជីវិតលើព្រះយេស៊ូដែលមានជីវិតរស់ឡើងវិញហើយ ជីវិតរបស់យើងមិនមែនតែនៅលើផែនដីនេះ គឺជីវិតរបស់យើងនៅស្ថិតស្ថេរអស់កល្បជានិច្ចនៅស្ថានបរមសុខ។ នេះណែនាំឲ្យយើងមានកម្លាំងនៅក្នុងជីវិតរបស់យើង ដូចសន្តប៉ូល ដូចសន្តសិលា ដូចសន្តយ៉ូហាន និងសន្តបុគ្គលទាំងអស់ គេពោរពេញដោយកម្លាំងដោយសារគេបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ និងដោយសារគេមានជំនឿលើព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។ គេយល់ហើយ ព្រះយេស៊ូមិនចោលគេទេ ព្រះយេស៊ូកំពុងនៅជាមួយគេរហូតដល់ទីបញ្ចប់លើផែនដីនេះ ជាពិសេសព្រះយេស៊ូបានទន្ទឹងរង់ចាំគេជាមួយព្រះបិតានៅឯស្ថានបរមសុខ។ ដូច្នេះគេពោរពេញដោយសេចក្តីក្លាហាន ដើម្បីទៅប្រកាសដល់ជនជាតិអ៊ីស្រាអែលអំពីលោកយេស៊ូ។ ប៉ុន្តែមុនគេចាប់ផ្តើមប្រកាសគេបានធ្វើសញ្ញាពិសេសមួយ មានមនុស្សពិការជើងដែលដើរមិនរួចប៉ុន្មានឆ្នាំហើយ ពេលនោះលោកសិលាថា "**លុយខ្ញុំឥតមានទេ ប៉ុន្តែអ្វីដែលខ្ញុំមានគឺឈ្មោះព្រះយេស៊ូគ្រីស្តខ្ញុំឲ្យអ្នកបាន សូមឈរឡើងហើយទៅចុះ**" ក្រោយមកបុរសម្នាក់នោះគាត់ឈរឡើងនឹងដើរបាន ប៉ុន្តែមិនមែនដោយសារគាត់ធ្វើបុណ្យទានតែដោយសារព្រះយេស៊ូគ្រីស្ត។ លោកសិលា និងលោកយ៉ូហាន បានបង្ហាញថានៅក្នុងឫទ្ធានុភាពដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ មនុស្សដែលពិការ មនុស្សដែលខ្វាក់ អាចដើរបាននិងមើលឃើញបាន។

ក្រោយមកអ្នកដឹកនាំសាសនា គេឆ្ងល់និងគេអន់ចិត្ត គេបានចាប់លោកទាំងពីរហើយហាមនិយាយអំពីព្រះយេស៊ូតទៅទៀត។ ប៉ុន្តែ នៅពេលនោះមានមនុស្សជាច្រើនបានចាប់ផ្តើមកែប្រែចិត្តគំនិតហើយដើរតាមព្រះយេស៊ូ។ ថ្ងៃនេះយើងឃើញម្តងទៀត គេបានហៅលោកសិលា និងលោកយ៉ូហានម្តងទៀត **មូលហេតុអ្វីនៅតែបន្តនិយាយអំពីព្រះយេស៊ូ?** ប៉ុន្តែលោកទាំងពីរនិយាយថា "**គេមិនអាចឈប់បានទេ ដោយឫទ្ធិបារមីរបស់ព្រះអង្គតែងតាំងលោកជាព្រះ**

**អម្ចាស់និងជាព្រះសង្គ្រោះ**"។ យើងត្រូវតែផ្តល់សក្ខីភាពដោយសារយើងជាសាក្សីផ្ទាល់ យើងផ្តល់សក្ខីភាពដោយសារយើងបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងជាគ្រីស្តបរិស័ទ ដោយទន្ទឹងរង់ចាំជីវិតអស់កល្បជានិច្ចជាមួយព្រះជាម្ចាស់ យើងជាគ្រីស្តបរិស័ទដោយដឹងថាតាមរយៈអភិបូជា តាមរយៈអគ្គសញ្ញាលើកលែងទោស យើងចូលនៅក្នុងជីវិតរបស់ព្រះជាម្ចាស់ដើម្បីទទួលការសង្គ្រោះនិងជីវិតថ្មី។ ប៉ុន្តែដើម្បីបម្រើជីវិតហ្នឹង ដើម្បីថ្វាយអភិបូជា ដើម្បីណែនាំបងប្អូននៅក្នុងព្រះសហគមន៍នីមួយៗ ប្រសិនបើយើងឥតមានបងប្រុសបងស្រី ឥតមានបូជាចារ្យយើងធ្វើដូចម្តេចបាន។

ប្រសិនបើយើងមិនភ្ញាក់ស្មារតី លោកឪពុករបស់យើងអស់កម្លាំងហើយដោយសារខ្វះជំនួយការ ដោយសារខ្វះកូនបូជាចារ្យដែលត្រៀមខ្លួនដើម្បីធ្វើជាបូជាចារ្យនៅថ្ងៃអនាគត។ យើងត្រូវការប្រកាសអស់ពីកម្លាំងកាយកម្លាំងចិត្តថា "**ខ្ញុំសុខចិត្តបម្រើព្រះអង្គ**"។ លោកឪពុកត្រូវការមានជំនួយការ ប៉ុន្តែមិនមែនតែអ្នកបម្រើអាសនៈទេ គឺជាអ្នកដែលចូលទេវវិទ្យាល័យដើម្បីត្រៀមខ្លួនធ្វើជាបូជាចារ្យ ដើម្បីបម្រើព្រះសហគមន៍ ដើម្បីឲ្យបងប្អូនទាំងអស់ដែលទន្ទឹងរង់ចាំសេចក្តីសង្ឃឹម ដែលទន្ទឹងរង់ចាំគ្រូគង្វាលដែលស្រឡាញ់ ដែលណែនាំ ដែលសួរសុខទុក្ខ។ យើងក៏ត្រូវការបងស្រីច្រើនដែរ បងស្រីយើងដែលខិតខំមកពីប្រទេសឆ្ងាយៗមកដើម្បីបម្រើ ប៉ុន្តែសព្វថ្ងៃបងស្រីខ្មែរយើងតិចណាស់។

យប់នេះយើងអធិដ្ឋាន ជាពិសេសឪពុកម្តាយ លោកតាលោកយាយ លោកឪពុក លោកអភិបាល ដើម្បីឲ្យកូនៗទាំងអស់គិតថានៅក្នុងអនាគតរបស់គេ គេអាចបម្រើព្រះសហគមន៍របៀបពិសេស ឲ្យយើងមានលោកសិលា លោកយ៉ូហាន លោកប៉ូលយ៉ាងច្រើន។ ដោយសារលោកទាំងអស់នេះ បានផ្តល់សក្ខីភាពនិងមានមនុស្សជាច្រើនបានដើរតាមព្រះយេស៊ូ។ ដូច្នេះសព្វថ្ងៃយើងត្រូវការមានលោកសិលា លោកយ៉ូហាន លោកប៉ូល ដើម្បីបម្រើព្រះសហគមន៍ ដើម្បីឲ្យមានគ្រូគង្វាលដែលណែនាំឲ្យព្រះសហគមន៍របស់យើងមានសេចក្តីសុខ និងមានកម្លាំងកាយកម្លាំងចិត្ត ដើម្បីឲ្យយើងទាំងអស់ជាពិសេសទទួលការសង្គ្រោះ មានន័យថាទទួលជីវិតអស់កល្បជានិច្ច។ យើងទូលអង្វរព្រះជាម្ចាស់ និងអរព្រះគុណព្រះអង្គ ដើម្បីឲ្យព្រះអង្គគង់នៅជាមួយយើងឲ្យយើងទទួលព្រះបន្ទូលរបស់ព្រះយេស៊ូនៅក្នុងដួងចិត្តរបស់យើង ដើម្បីហ៊ានឆ្លើយតបនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់ថា "**ខ្ញុំសុខចិត្តបម្រើអស់មួយជីវិត**"។ អាម៉ែន៕